**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រកាសទ្រព្យសម្បត្តិ និងបំណុល តាមរបប ០២ឆ្នាំ សម្រាប់ឆ្នាំ២០១៧

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា** ដែលជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុលទាំងអស់ មេត្តាជ្រាបថា ផ្អែកតាមគោលការណ៍កំណត់របស់អង្គភាពប្រឆាំងអំពើពុករលួយ ការប្រកាសទ្រព្យសម្បត្តិ និងបំណុល របស់បុគ្គលជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល តាមរបប០២ឆ្នាំ សម្រាប់ឆ្នាំ២០១៧ ត្រូវគិតចាប់ពីថ្ងៃទី**០១ ដល់ ៣១ ខែមករា ឆ្នាំ២០១៧** នេះ។ ដោយឡែកសម្រាប់ **ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើឡើងនៅសប្តាហ៍ទី៤ គិតចាប់ពីថ្ងៃទី២៣-៣១ ខែមករា ឆ្នាំ២០១៧** ខាងមុខនេះ។

ការប្រកាសនេះ ធ្វើឡើងចំពោះ **ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា** ដែលធ្លាប់បានប្រកាសទ្រព្យសម្បត្តិ និងបំណុល ក្នុងឆ្នាំ២០១៥ និង**ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា** ដែលទើបតែងតាំងមានឋានៈចាប់ពីប្រធាននាយកដ្ឋានឡើង ហើយមិនទាន់បានប្រកាស ទ្រព្យសម្បត្តិ និងបំណុល ត្រូវរួសរាន់បំពេញទម្រង់នៃការប្រកាសទ្រព្យសម្បត្តិ និងបំណុល រួចផ្ញើទៅកាន់**អង្គភាពប្រឆាំងអំពើពុករលួយ** តាមរយៈជនបង្គោលនីមួយៗដូចខាងក្រោម៖

| | |
|---|---|
| ១. ឯកឧត្តម **ហេង សួរ** | សម្រាប់ថ្នាក់ដឹកនាំ និងទីប្រឹក្សាក្រសួង ព្រមទាំងអង្គភាពអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋាន គ.ក.ប នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត |
| ២. ឯកឧត្តម **សេង សក្ដា** | សម្រាប់អង្គភាពអគ្គនាយកដ្ឋានការងារ អគ្គាធិការដ្ឋាន និងបេឡាជាតិ របបសន្តិសុខសង្គម |
| ៣. ឯកឧត្តម **ឡៅ ហ៊ីម** | សម្រាប់អង្គភាពអគ្គនាយកដ្ឋាន អ.ប.ប.វ ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសក្រោមឱវាទក្រសួង |

ចំពោះទម្រង់នៃការប្រកាសទ្រព្យសម្បត្តិ និងបំណុល អាចស្វែងរកបាននៅ**នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក** ឬអាចទាញយកចេញពីគេហទំព័ររបស់អង្គភាពប្រឆាំងអំពើពុករលួយ **www.acu.gov.kh**។

អាស្រ័យហេតុនេះ សូមបុគ្គលជាប់កាតព្វកិច្ចប្រកាសទាំងអស់ មេត្តារួសរាន់មកប្រកាសទ្រព្យសម្បត្តិ និងបំណុល របស់ខ្លួនឱ្យបានទាន់ពេលវេលា តាមគោលការណ៍កំណត់របស់អង្គភាពប្រឆាំងអំពើពុករលួយ និងសូមថតចម្លងស្រោមសំបុត្រដែលប្រកាសរួចបញ្ជូនមក**នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក** ផងដែរ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១៦